# សេចក្តីថ្លែងការណ៍រួម

គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ និង អង្គការសង្គមស៊ីវិល ជាពិសេសអង្គការសង្គមស៊ីវិលដែលមានស្ត្រីជាអ្នកដឹកនាំ មានការសោកស្តាយយ៉ាងខ្លាំងចំពោះការលុបរូបស្ត្រីដេរប៉ាក់នៅលើ ជញ្ជាំងអាគារប៊ូឌីញកាលពីយប់ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៥ ដែលគូរដោយវិចិត្រករជនជនអាមេរិក ។

យើងខ្ញុំយល់ឃើញថារូបគំនូរនេះ បានបង្ហាញអំពីតួនាទី និងការរួមចំណែករបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច និងការផ្សាភ្ជាប់សិល្បៈក្នុងការឆ្លុះបញ្ចាំងអំពីជីវភាពរស់នៅជាក់ស្តែងរបស់ស្ត្រី និងការកសាងសង្គមកម្ពុជាក្រោយពេលសង្គ្រាមរ៉ាំរ៉ៃកន្លងផុតទៅ។ ក្រុមស្ត្រីយើងបានឆ្លងកាត់យ៉ាងលំបាក ក្នុងការតស៊ូស្វិតស្វាញអំឡុងពេល និងក្រោយសង្គ្រាម និងពេលបច្ចុប្បន្នក្នុងការទ្រទ្រង់គ្រួសារ និងសង្គមផងដែរ។ ការលុបរូប គំនូរនេះ ចោលបានធ្វើឲ្យមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងពីសាធារណៈជន ជាពិសេសតាមរយៈអ្នកប្រើប្រាស់បណ្តាញសង្គម ដែលបានលើកឡើងពីការមិនពេញចិត្តចំពោះចំណាត់ការរបស់សាលាក្រុងភ្នំពេញ ដែលបង្ហាញអោយឃើញពី ការដោះស្រាយបញ្ហាដែលមិនមានការទទួលខុសត្រូវ និងមិនសមស្របនឹងសភាពការណ៍ ដែលការចាត់វិធានការណ៍របស់សាលាក្រុងភ្នំពេញ គួរតែត្រូវបានធ្វើឡើងក្នុងកំឡុងពេលគូរ ប្រសិនបើដូចជាការលើកឡើងថា ការគូរនេះគ្មានច្បាប់អនុញ្ញាត។

យើងខ្ញុំសូមអំពាវនាវដល់រាជរដ្ឋាភិបាលពិនិត្យ និងពិចារណាឡើងវិញចំពោះចំណាត់ការរបស់សាលាក្រុងភ្នំពេញ ដោយធ្វើការសុំទោសជាសាធារណៈចំពោះការលុបរូបគំនូរនេះចោល ដើម្បីជៀសវាងនូវការបកស្រាយផ្សេងៗពីគ្នា ដែលធ្វើឲ្យប៉ះពាល់ដល់ការខិតខំប្រឹងប្រែងរបស់ប្រមុខរដ្ឋាភិបាលកម្ពុជាក្នុងការប្តេជ្ញាចិត្ត បង្កើនការវិនិយោគលើសមភាពយេនឌ័រ និងបន្តការលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច និងភាពជាអ្នកដឹកនាំ ក៏ដូចជាបង្ហាញពីការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ ក្នុងការស្តាប់មតិយោបល់របស់រាស្ត្រ និងបង្ហាញអំពីកិច្ចប្រឹងប្រែងក្នុងលើកកម្ពស់តម្លៃការងាររបស់ស្ត្រី ក្នុងការកសាងសង្គមល្អ សម្រាប់យើងទាំងអស់គ្នា និងតម្លៃសិល្បៈសហគមន៍យើង។

**រាយនាមអ្នកគាំទ្រសេចក្តីថ្លែងការណ៍៖**

១. លោកស្រី ប្រ៊ុក វ៉ាន្នី នាយិកាប្រតិបត្តិអង្គការដៃគូអភិវឌ្ឍន៍

២. លោកស្រី ម៉ាក ច័ន្ទស៊ីថា

៣. លោកស្រី ចាន់ គន្ធា

៤. លោកស្រី ជីវ លីនណា

៥.លោកស្រី ចាន់ សោភ័ណ្ឌ

**ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**

- លោកស្រី ធីតាឃិះ នាយិកាប្រតិបត្តិអង្គការសីលការ និងជាប្រធាន គ.ស.ន

លេខទូរស័ព្ទ ០១២ ៨៣៨ ៤៦៤